# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១៥
## និងទិសដៅការងារ ខែមេសា ឆ្នាំ២០១៥

( ពីថ្ងៃទី២៦/០២/២០១៥ ដល់ ២៥/០៣/២០១៥ )

ក្នុងគោលដៅចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពី ខែកុម្ភៈ ឆ្នាំ២០១៥ កន្លងទៅ សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

នៅក្នុងខែមីនាឆ្នាំ២០១៥នេះ មានការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានប្រតិបត្តិការដោយ មន្ទីរប្រឆាំងគ្រឿងញៀន និងបណ្តាស្នងការដ្ឋាននគរបាល ក៏ដូចជាបញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី-ខេត្ត ចំនួន ២១ គឺរាជធានីភ្នំពេញ, បន្ទាយមានជ័យ, បាត់ដំបង, កំពង់ចាម, កំពង់ឆ្នាំង, កំពង់ស្ពឺ, កំពង់ធំ, កំពត, មណ្ឌលគិរី, ព្រះវិហារ, ព្រៃវែង, ពោធិ៍សាត់, រតនគិរី, សៀមរាប, ព្រះសីហនុ, កណ្តាល, ស្ទឹងត្រែង, តាកែវ, ឧត្តរមានជ័យ, ប៉ៃលិន និង ខេត្តត្បូងឃ្មុំ ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបដោយសមត្ថកិច្ចអនុវត្តន៍ច្បាប់ខាងលើ មានបទល្មើសគ្រឿងញៀន២ករណីធំៗ ដែល ១ ករណី បង្ក្រាបដោយកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀន សហការជាមួយស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងចាប់យកមេតំហ្វេតាមីន ICE ចំនួន ៧៨៤,០៣ ក្រាម និង ១ ករណីទៀតបង្ក្រាបដោយកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង និងចាប់យកមេតំហ្វេតាមីន ICE ចំនួន ១.៦៥២,២ ក្រាម ។

## II. ការងារដឹកនាំ

### ១. ការងារដឹកនាំស្ថាប័នកំពូលថ្នាក់ជាតិ

ថ្នាក់ដឹកនាំនៃស្ថាប័នកំពូលរបស់ជាតិដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខ បានបន្តណែនាំ និងដឹកនាំនូវគោលការណ៍សំខាន់ៗ ក្នុងសកម្មភាពការងារ

ប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ ៖

- ផ្តល់អនុសាសន៍ជូនដល់អង្គសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០១៤-២០១៥ ដែលនៅក្នុងចំណុចទី៦ វាក្យខណ្ឌ២ មានខ្លឹមសារថា "ផ្សារភ្ជាប់ការប្រយុទ្ធប្រឆាំងអំពើហឹង្សា ទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ លុបបំបាត់ការប្រើប្រាស់គ្រឿងញៀន ការជួញដូរស្រ្តី កុមារ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងគ្រប់ប្រភេទក្នុងសង្គម"
- អនុញ្ញាតឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤ និងលើកទិសដៅការងារ ឆ្នាំ២០១៥ ។

## ២. ភាពការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំលើការងារជាគោលសំខាន់ៗ មានជាអាទិ៍ ៖

- ចេញសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
- រៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥
- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវជំរុញលើការងាររៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន), ការប្រឡងប្រជែងតែងកំណាព្យ ដែលមានខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការផលិតឯកសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- ពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ ជាមួយនេះ ត្រូវពង្រីកកម្មវិធីព្យាបាលដោយផ្អែកលើសហគមន៍ និងរៀបចំជាយន្តការដាក់លាក់តាមខ្លឹមសារបីគឺ ការព្យាបាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្ម ។
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវបន្តជំរុញ ៖
  - ការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (មណ្ឌលរបស់រដ្ឋ និង ឯកជន)
  - ការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅរាជធានីភ្នំពេញ ឱ្យបានឆាប់រហ័ស
  - ការរៀបចំខិត្តប័ណ្ណផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងខិត្តប័ណ្ណផ្សព្វផ្សាយពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
  - ការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀតពីកម្មវិធីម្ទុល/ស៊ីរ៉ាំង ការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលសុខភាព-មន្ទីរពេទ្យបង្អែក និងការផ្តល់សេវាព្យាបាលរបស់អង្គការមិត្តសំឡាញ់
  - ការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាអ្នកញៀន គ្រឿងញៀននៅក្នុងពន្ធនាគារ
  - ការជំរុញសាលារាជធានីភ្នំពេញឱ្យអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៥ ពិសេសដំណើរការព្យាបាលដោយផ្អែកលើសហគមន៍ ដោយពង្រឹងយន្តការគ្រប់គ្រងលើការ ព្យាបាល បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម
  - ការរៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញពាក់ព័ន្ធនឹងការចោទ

ប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក

- ការធ្វើសម្រង់ទិន្នន័យបទល្មើសនានា ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន និងបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរជនល្មើសឱ្យបានច្បាស់លាស់
- ការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ដែលនៅក្នុងដែនសមត្ថកិច្ចតុលាការ
- ការរៀបចំព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

នៅក្នុងខែមីនាឆ្នាំ២០១៥នេះ ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារ ដែលបានដាក់ចេញកាលពីខែកុម្ភៈឆ្នាំ២០១៥ កន្លងទៅ ក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត នៅតែបន្តអនុវត្តកម្មវិធីអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ តាមរយៈស្ថានីយវិទ្យុជាតិ វិទ្យុរាជធានី ខេត្ត តាមកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

ដោយឡែក ការអប់រំពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ ក្រៅពីការចូលរួមដោយក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក៏មានការចូលរួមអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ ដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៧ គឺ ខេត្តបាត់ដំបង, ក្រចេះ, ប៉ៃលិន, កំពង់ស្ពឺ, កណ្តាល, កំពង់ឆ្នាំង និងខេត្តកំពង់ចាម ។ លទ្ធផលជារួម មានមហាជនចូលរួមប្រមាណ **២២២.៧១២** នាក់ លើ **១៩២.២១៨** នាក់ នៃខែកុម្ភៈ ឆ្នាំ ២០១៥ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១) ។

ក្នុងចំណោមសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តនូវការងារដូចខាងក្រោម ៖

- រៀបចំ និងអញ្ជើញក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងទេសចរណ៍ ដើម្បីចូលជាវាគ្មិនផ្តល់បទសម្ភាសន៍ក្នុង ៖
  - កម្មវិធី**ព័ត៌មានពេលថ្ងៃ**របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្រោមប្រធានបទ ស្តីពីការងារស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
  - កម្មវិធី**ចក្ខុវិស័យកម្ពុជា**របស់ស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្រោមប្រធានបទ ស្តីពីការអប់រំ បង្ការ បញ្ហាគ្រឿងញៀនក្នុងវិស័យទេសចរណ៍ កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
- រៀបចំកម្មវិធីជូនក្រុមអ្នកយកព័ត៌មានសម្រាប់កម្មវិធី សភាអ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ដើម្បីជួបសម្ភាសន៍ជាមួយអ្នកសម្រាកព្យាបាលភាពញៀនគ្រឿងញៀន នៅក្នុងមណ្ឌលឱកាសខ្ញុំ ក្រោមប្រធានបទស្តីពី បទពិសោធន៍ជោគជ័យក្នុងការផ្តាច់គ្រឿងញៀន កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
- ចូលរួមសន្និសីទសារព័ត៌មានមហោស្រពតន្ត្រី និងចម្រៀងសម័យថ្នាក់ជាតិ ឆ្នាំ២០១៥
- គាំទ្រសកម្មភាពរបស់ ៖

- សមាគមយុវជនខ្មែរ ក្នុងការបន្តបើកវគ្គបណ្ដុះបណ្ដាល ការសម្ដែងរឿងខ្លី ការចងក្រងសកម្មភាពអប់រំរបស់បណ្ដាញយុវជន ការចុះប្រមូលព័ត៌មាន/ទិន្នន័យ និងសិក្ខាសាលាស្ដីពីការលើកកម្ពស់ ការចូលរួមរបស់យុវជនក្នុងការអប់រំ បង្ការ គ្រឿងញៀន និងគ្រឿងស្រវឹង
- អង្គការ កាកូ (CACO) ក្នុងការផ្សព្វផ្សាយអប់រំពីបញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន នៅខេត្តពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ឧត្ដរមានជ័យ និងខេត្តព្រះវិហារ

- ស្នើសុំទៅក្រសួងព័ត៌មាន, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងធម្មការនិងសាសនា, សហភាពសហព័ន្ធយុវជនកម្ពុជា, សមាគមសិល្បករ និងសមាគមទូរទស្សន៍កម្ពុជា ដើម្បីជួយជំរុញការផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិខ្មែរ
- បន្តការកែសម្រួលលើខ្លឹមសារខិត្តប័ណ្ណផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងខិត្តប័ណ្ណផ្សព្វផ្សាយពីការផ្ដល់សេវាព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- បន្តសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ ទូរទស្សន៍បាយ័ន, ទូរទស្សន៍ហង្សមាស, ម៉ាយធីវី និង ស៊ី.ធី.អិន បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈកម្មវិធីប្រគំតន្ត្រីស្រុកស្រែ, កម្មវិធីតន្ត្រីទេសចរណ៍ខារ៉ាបាវ, តន្ត្រីកូកាកូឡា, សេដ្ឋីគូបូតា និង តន្ត្រីទេសចរណ៍ស្មាត នៅខេត្តព្រៃវែង, កំពត, មានមហាជនចូលរួមប្រមាណ ១៤៦.០០០ នាក់ ។
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុង**ខែមីនា ឆ្នាំ២០១៥** មានអ្នកអានចំនួន **៣៣.១៨៣** ដង លើ **២៨.៧៥២** ដង នៃខែកុម្ភៈ ឆ្នាំ២០១៥ ។

## ២. ការព្យាបាល ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### *២.១. ការកាត់បន្ថយគ្រោះថ្នាក់*

- បានចាត់តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន ០២ រូប ចូលជាសមាជិកក្នុងគណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ
- បានចូលរួមបំពេញលើទម្រង់ប្រមូលទិន្នន័យសម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៥

### *២.២. ការព្យាបាល ស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន*

- បាននិងកំពុងរៀបចំឯកសារពាក់ព័ន្ធនឹងការស្នើសុំឱសថ ប៊ុងសៃន សម្រាប់ព្យាបាលអ្នកញៀនអាភៀននៅកម្ពុជា
- បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ក្នុងការរៀបចំរបាយការណ៍ស្ដីពីលទ្ធផលនៃការព្យាបាល និង ស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាននៅកម្ពុជា ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### *៣.១. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់*

- អគ្គស្នងការដ្ឋាននគរបាលជាតិ បានដំឡើងបញ្ជីឈ្មោះជនសង្ស័យពាក់ព័ន្ធបទល្មើសគ្រឿងញៀន ជាមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក្នុងឆ្នាំ២០១៤ សរុបមានចំនួន **៣៧** នាក់ (មន្ត្រីរាជការ ០៦

នាក់, នគរបាល ០៨ នាក់, អាវុធហត្ថ ០៤ នាក់, យោធា ១៩ នាក់)

- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានដំឡើងបញ្ជីឈ្មោះជនសង្ស័យពាក់ព័ន្ធបទល្មើសគ្រឿងញៀន ជាមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក្នុងឆ្នាំ២០១៤ សរុបមានចំនួន **១៥** នាក់ (មន្ត្រីរាជការ ០១ នាក់, នគរបាល ០៥ នាក់, យោធា ០៩ នាក់)

  **សរុបរួម ៥២ នាក់** (មន្ត្រីរាជការ ០៧ នាក់, នគរបាល ១៣ នាក់, អាវុធហត្ថ ០៤ នាក់, យោធា ២៨ នាក់)

- រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន តាមប្រព័ន្ធអេឡិចត្រូនិច (E-Learning) នៅបណ្ឌិត្យសភានគរបាលកម្ពុជា កាលពីថ្ងៃទី១៩-២០ ខែមីនា ឆ្នាំ២០១៥
- បានចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់នៃខេត្តកោះកុង ពោធិ៍សាត់ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ទៅចូលរួមសិក្ខាសាលាស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនតាមព្រំដែនកម្ពុជា-ថៃ កាលពីថ្ងៃទី២៥-២៧ ខែមីនា ឆ្នាំ២០១៤ នៅទីក្រុងប៉ាតាយ៉ា ប្រទេសថៃ (មន្ត្រីអគ្គលេខាធិការដ្ឋាន **០៣** រូប មន្ត្រីពាក់ព័ន្ធ **២០** រូប)

## *៣.២.* លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុបរួម **១៥៩ ករណី** លើ ១៨៤ ករណី នៃខែកុម្ភៈ ឆ្នាំ២០១៥
- ជនសង្ស័យឃាត់ខ្លួន សរុបរួម **៣៣០ នាក់** (ស្រី ៣៤ នាក់) លើ ៤២២ នាក់ នៃខែកុម្ភៈ ឆ្នាំ២០១៥
  - ក្នុងចំនួនបទល្មើសគ្រឿងញៀន **១៥៩ ករណី** និងជនសង្ស័យទាំង **៣៣០ នាក់** ខាងលើគឺ ៖
    - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចនគរបាលជាតិ **១២៦ ករណី**, ជនសង្ស័យ **២៤០ នាក់** (ស្រី ២២ នាក់)
    - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយសមត្ថកិច្ចកងរាជអាវុធហត្ថ **៣៣ ករណី**, ជនសង្ស័យ **៩០ នាក់** (ស្រី ១២ នាក់)
  - ក្នុងចំនួនជនសង្ស័យ ដែលបានឃាត់ខ្លួនទាំង ៣៣០ នាក់ ខាងលើ មាន ៥ សញ្ជាតិ គឺ ខ្មែរ ៣១៣ នាក់ (ស្រី ២៨ នាក់), វៀតណាម ១៣ នាក់ (ស្រី ៦ នាក់), អង់គ្លេស ២ (ប្រុស), អាល្លឺម៉ង់ ១ នាក់ (ប្រុស), ឡាវ ១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំ រឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក** មេតំហ្វេតាមីន WY ១៩២,៥៣ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ ICE ៣.២៤០,០៩ ក្រាម, ហេរ៉ូអ៊ីន ០,០២ ក្រាម, កញ្ឆាក្រៀម ៨៥.២០ ក្រាម
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** ដែលបានចាប់យករួមមាន ម៉ូតូ ៨៤ គ្រឿង, រថយន្ត ១ គ្រឿង, ប្រាក់កម្ពុជា ៥.១៨៤.៧០០ រៀល, ប្រាក់ថៃ ១៨៩ បាត, ប្រាក់អាមេរិក ៨០៩ ដុល្លារ (**ដូចមានក្នុងតារាង ឧបសម្ព័ន្ធទី២**)
- ជនសង្ស័យចាប់តាមដីកា មាន ១៥ ដីកា = មនុស្ស ១៥ នាក់ (ស្រី ២ នាក់) ជនជាតិខ្មែរ
- ការធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ក្នុងខែមីនា ឆ្នាំ២០១៥ សរុបចំនួន ១៣៧ សំណាក = ១២២ ករណី ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន មាន ១៣៥ សំណាក = ១២១ ករណី ៖**

-មេតំហ្វេតាមីន ICE ១០០ សំណាក = ៧២,៩៩ %

-មេតំហ្វេតាមីន WY ២៤ សំណាក = ១៧,៥១ % -កេតាមីន ០១ សំណាក = ០,៧២ %

-ហេរ៉ូអ៊ីន ០៦ សំណាក = ៤,៣៧ % -កញ្ឆា ០១ សំណាក = ០,៧២ %

-MDMA ០១ សំណាក = ០,៧២ % -តេត្រាអ៊ីដ្រូកាណាប៊ីណុល ០១ សំណាក = ០,៧២ %

- **សំណាកអវិជ្ជមានសារធាតុញៀន ០២ សំណាក = ១ ករណី**

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំពាក់ព័ន្ធនឹងតារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានបទដ្ឋានបច្ចេកទេសឱ្យនាំចូលនៅក្នុងខែមីនា ឆ្នាំ២០១៥ នេះ សរុបមានចំនួន ៨៦១.៦០០ គ.ក្រ ក្នុងនោះ ៖
  - សារធាតុគីមីផ្សំពាក់ព័ន្ធនឹងតារាងទី **IV** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានបទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានចំនួន **៨០០.០០០** គ.ក្រ
  - សារធាតុគីមីផ្សំពាក់ព័ន្ធនឹងតារាងទី **IV** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានបទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានចំនួន **៦១.៦០០** គ.ក្រ
- បាននិងកំពុងបន្តកិច្ចសហការជាមួយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពាក់ព័ន្ធនឹងនីតិវិធីក្នុងការប្រគល់ជូនក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីគ្រប់គ្រងបន្តនិងចាត់ចែងតាមសមត្ថកិច្ចនូវសារធាតុគីមី ចំនួន ១៤ មុខ ទម្ងន់ ១៨ តោន ៩០០ គីឡូក្រាម (រងចាំសាលក្រមស្ថាពរ)
- បានរៀបចំបញ្ជូនសំណាកម្សៅវល្លិរមៀតទៅអង្គការ UNODC ធ្វើការវិភាគឱ្យបានច្បាស់លាស់ថា នៅក្នុងម្សៅនោះ មានផ្ទុកនូវសារធាតុអ្វីខ្លះ
- បាននិងកំពុងបន្តការរៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធការចរាចរ ការរើបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- បាននិងកំពុងបន្តយកចិត្តទុកដាក់ជំរុញការរៀបចំកិច្ចប្រជុំទ្វេភាគីថ្នាក់ខេត្ត ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ឡាវ ថៃ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនឱ្យបានទៀងទាត់
- បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើការងារអនុវត្តន៍ច្បាប់ និងការត្រួតពិនិត្យគ្រឿងញៀន ជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ
- បានសម្របសម្រួលជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ទៅចូលរួមសិក្ខាសាលាស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនតាមព្រំដែនកម្ពុជា-ថៃ កាលពី ថ្ងៃទី២៥-២៧ ខែមីនា ឆ្នាំ២០១៤ នៅទីក្រុងប៉ាតាយ៉ា ប្រទេសថៃ
- បានសម្របសម្រួលដំណើរទស្សនកិច្ច ជូនគណៈប្រតិភូជាន់ខ្ពស់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅកាន់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- បានជួបពិភាក្សាការងារជាមួយ គណៈប្រតិភូប្រទេសអូស្ត្រាលី កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា
- បានចូលរួមកិច្ចប្រជុំក្រុមការងារអន្តរភ្នាក់ងារ លើកទី២ ស្តីពីការអនុវត្តច្បាប់ កាលពី ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ នៅប្រទេសហ្វីលីពីន (ចូលរួមដោយតំណាងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសហ្វីលីពីន)
- បាននិងកំពុងពិនិត្យឡើងវិញ លើអនុស្សរណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខាកន្លងមក រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយនគរបាលសហព័ន្ធអូស្ត្រាលី ដើម្បីត្រៀមអនុវត្តបន្តរយៈ ពេល ២ ឆ្នាំទៀត
- បន្តការគាំទ្រគម្រោង ភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងគ្រឿងញៀន (PATROL) ដំណាក់កាលទី២
- ចូលរួមពិនិត្យលើសេចក្តីព្រាង ចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ចូលរួមកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥)
- ចូលរួមកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ និងពិធីចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចសហប្រតិបត្តិការ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំឆ្នាំ២០១៥ (ថ្ងៃទី២៣/៣/២០១៥)
- បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន ។

# IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១៥

## ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- រៀបចំ និងអញ្ជើញវាគ្មិនជាតំណាងមកពីក្រសួងព័ត៌មាន, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងធម្មការនិងសាសនា ដើម្បីផ្តល់កិច្ចសម្ភាសន៍ នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្នុងកម្មវិធី ៖
  - ✓ ព័ត៌មានពេលថ្ងៃ ស្តីពីការងារអប់រំផ្សព្វផ្សាយដើម្បីបង្ការពីបញ្ហាគ្រឿងញៀន តាមរយៈប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥
  - ✓ ចក្ខុវិស័យកម្ពុជា ក្រោមប្រធានបទស្តីពី ការអប់រំផ្សព្វផ្សាយដើម្បីបង្ការពីបញ្ហាគ្រឿងញៀន តាមរយៈវិស័យសិល្បៈ និងវប្បធម៌ នៅកម្ពុជា
  - ✓ សភាអ៊ីនធឺណែត ក្រោមប្រធានបទស្តីពី ការងារអប់រំផ្សព្វផ្សាយដើម្បីបង្ការពីបញ្ហាគ្រឿងញៀន តាមរយៈពុទ្ធ

សាសនា នៅកម្ពុជា

- រៀបចំសកម្មភាពអប់រំផ្សព្វផ្សាយស្តីពីបញ្ហាគ្រឿងញៀន ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ថ្ងៃទី១៤-១៦ ខែមេសា ឆ្នាំ២០១៥
- បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យ ឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន
- បន្តជំរុញក្រសួងអប់រំ យុវជន និងកីឡា លើការងាររៀបចំសាលារៀនបៃតង (សាលារៀនគ្មានគ្រឿងញៀន), ការងារប្រឡងប្រជែងតែងកំណាព្យដែលមានខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការផលិត ឯកសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស
- បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមប្រព័ន្ធផ្សព្វផ្សាយនានា
- បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលអប់រំពីបញ្ហាគ្រឿងញៀននៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និង នៅតាមសហគមន៍
- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តគោលដៅ និងវិស័យឯកជន ដើម្បីបន្តការបញ្ជ្រាបការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជន

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន**

- ជំរុញសកម្មភាពចែកចាយឯកសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ឱ្យកាន់តែសកម្មថែមទៀតនៅតំបន់គោលដៅសំខាន់ៗ ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានយល់ជ្រួតជ្រាបនិងទៅទទួលយកសេវាព្យាបាល នៅមន្ទីរពេទ្យបង្អែក ឬ មណ្ឌលសុខភាព ដែលនៅជិត
- ចូលរួមសិក្ខាសាលាស្តីពី ការផ្ទៀងផ្ទាត់លើក្របខណ្ឌសម្រាប់ការងារតាមដានវាយតម្លៃ (M & ELog Frame) ផែនការយុទ្ធសាស្ត្រជាតិ លើកទី៤ ឆ្លើយតបទូលំទូលាយ និងពហុវិស័យ ទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ (ឆ្នាំ២០១៥-២០២០)
- ចូលរួមកិច្ចប្រជុំក្រុមការងារចម្រុះរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ (ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥)
- ជំរុញក្រសួងសុខាភិបាល រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅកម្ពុជា សម្រាប់ធ្វើជាមូលដ្ឋានបន្តការកៀរគរថវិកាជំនួយ
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សហការជាមួយអង្គការ UNODC ដើម្បីធ្វើការបូកសរុបលទ្ធផល នៃការកៀរគរថវិកាជំនួយសម្រាប់អនុវត្តកម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការពង្រឹង

យន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- បន្តការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តការផលិតស្លាកសញ្ញា ដើម្បីដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួចក្នុងរាជធានីភ្នំពេញ និងជំរុញការផលិតខិត្តប័ណ្ណផ្សព្វផ្សាយពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀត ពីកម្មវិធីម្ជុល/ស៊ីរ៉ាំង និងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងសេវាព្យាបាលរបស់អង្គការមិត្តសំឡាញ់
- រៀបចំកិច្ចប្រជុំជាមួយតំណាងអយ្យការនិងតុលាការ ពិសេសនៅរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាលនៅតាម មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
- ចូលរួមប្រជុំជាមួយសាលារាជធានីភ្នំពេញ ដើម្បីធ្វើការត្រួតពិនិត្យលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងរកវិធានការបន្តពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- ចូលរួមសិក្ខាសាលាស្តីពី ការផ្ទៀងផ្ទាត់លើរបាយការណ៍វឌ្ឍនភាពជាសាកលឆ្លើយតបជាតិពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ (GARPR) ឆ្នាំ២០១៥ ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

- បន្តចូលរួមសហការជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទនៅតាមតំបន់ប្រតិបត្តិការសឹករងចំនួន ១២ និងសាលានាយទាហានចំនួន ៣
- ត្រៀមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់ច្រកអាកាសយានដ្ឋានអន្តរជាតិ
- រៀបចំវគ្គបណ្តុះបណ្តាល បំប៉នជំនាញស្តីពីការស្រាវជ្រាវស៊ើបអង្កេត ការកសាងឯកសារសំណុំរឿង នីតិវិធី ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដល់មន្ត្រីនគរបាលដែលមានភារកិច្ចពាក់ព័ន្ធ នៅតាមបណ្តាខេត្តគោលដៅ
- បន្តការធ្វើសម្រង់ទិន្នន័យបទល្មើសនានា ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀននិងបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរជនល្មើសឱ្យបានច្បាស់លាស់
- បន្តជំរុញការធ្វើសម្រង់ទិន្នន័យសំណុំរឿងបទល្មើសគ្រឿងញៀន ជាមួយក្រសួងយុត្តិធម៌
- បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រ(CBT) នៅនឹងកន្លែង (នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣)
- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិច (E-Learning)
- ចុះពង្រឹងតាមដានការអនុវត្តច្បាប់ និងការអនុវត្តសាលក្រមតុលាការ របស់មន្ត្រីអនុវត្តន៍ច្បាប់នៅតាម រាជធានីខេត្តគោលដៅ
- ត្រៀមរៀបចំពិធីប្រកាសសមាសភាព តួនាទី ភារកិច្ចរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- រៀបចំឯកសារសម្រាប់បណ្ដុះបណ្ដាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ស្ដីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់
- បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្ដីព្រាងប្រកាសស្ដីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- សិក្សាស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន
- រៀបចំឯកសាររបាយការណ៍សំយោគពាក់ព័ន្ធនឹងការចរាចរ ការរឹបអូសប្រេងម្រះព្រៅភ្នំ កន្លងមក ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- សម្របសម្រួលជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ចំនួន ២០ នាក់ ទៅចូលរួមសិក្ខាសាលាស្ដីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងការិយាល័យ BLO កម្ពុជាថៃ នៅថ្ងៃទី ០៧-១០ ខែមេសា ឆ្នាំ២០១៥ នៅខេត្តសុរិន ប្រទេសថៃ
- សម្របសម្រួលជាមួយប្រទេសថៃ ឡាវ វៀតណាម ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងថ្នាក់ខេត្តនិងខេត្ត ស្រុកនិងស្រុកជាប់ព្រំដែនកម្ពុជា-ថៃ / កម្ពុជា-ឡាវ / កម្ពុជា-វៀតណាម ស្ដីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដោយមានការចូលរួមពីផ្នែកកងទ័ព
- ពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា- ថៃ / កម្ពុជា-ឡាវ និង កម្ពុជា-វៀតណាម
- អនុវត្តកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការលើការងារអនុវត្តន៍ច្បាប់ និងការត្រួតពិនិត្យគ្រឿងញៀន ដែលបានចុះហត្ថលេខាជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)
- សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន ប្រទេសឡាវ និង ប្រទេសវៀតណាម ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសឡាវ និងវៀតណាម។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីកិច្ចសហប្រតិបត្តិការសន្តិសុខតំបន់អាស៊ី ប៉ាស៊ីហ្វិក (ADEC) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃ ទី០១ ខែមេសា ដល់ ០៧ ខែឧសភា ឆ្នាំ២០១៥
- បន្តការចូលរួមគ្រប់វេទិកា ទាំងក្នុងតំបន់ និងអន្តរជាតិ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការជួញដូរគ្រឿងញៀនខុសច្បាប់ ឆ្លងកាត់កម្ពុជាទៅកាន់បណ្ដាប្រទេសនានានៅក្នុងតំបន់
- បន្តចូលរួមក្នុងយន្តការត្រួតពិនិត្យគ្រឿងញៀនជាមួយបណ្ដាប្រទេសអាស៊ាន
- បង្កើនកិច្ចសហការជាមួយអង្គការ UNODC ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនតាមយន្តការនៃបណ្ដាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ
- សម្របសម្រួលរៀបចំដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- រៀបចំសេចក្ដីព្រាងផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន

- បន្តការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់វិធីសាស្ត្រព្យាបាល ការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន
- ជំរុញការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយនិងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន
- បន្តជំរុញការរៀបចំយន្តការគណៈកម្មការអនុវត្តផែនការត្រួតពិនិត្យគ្រឿងញៀន ពីថ្នាក់រាជធានីរហូតដល់ខណ្ឌ សង្កាត់ដើម្បីចូលរួមចំណែកក្នុងការគាំទ្រកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហ-គមន៍ ដោយធ្វើសកម្មភាពនៅតំបន់គោលដៅសំខាន់ៗ
- ជំរុញការរៀបចំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាគ្រឿងញៀននៅក្នុងពន្ធនាគារ
- រៀបចំកម្មវិធីផ្សព្វផ្សាយអំពី អនុសញ្ញាអន្តរជាតិស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍ រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

"ដើម្បីជូនជ្រាប "

- ក្រសួង សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ "

- ឯកសារ